ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៧៧ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ២៨ រូប ៩៤៩៧

២២-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **យ៉ុខ ហេខ** ជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បំណាច់មុខងារ ៩៤៩៨


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២២-១២-២០២១ -អនុក្រឹត្យលេខ ២៥៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៤៩៩

២២-១២-២០២១ -អនុក្រឹត្យលេខ ២៥៦ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៥០២

៣០-១២-២០២១ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ចមន្ត្រីរាជការ ៩៥០៤


## III~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


៩-៩-២០២១ -ប្រកាសលេខ ៥៤៤ សហវ.ប្រក ស្តីពី សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា ៩៥០៦


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


៨-៦-២០២១ -ប្រកាសលេខ ១៨៣ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វីនក្រោន (ខេមបូឌា) អ៊ិនដាសស្រ្ទៀល ឯ.ក បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ៩៥៣៣

៨-៦-២០២១ -ប្រកាសលេខ ១៨៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន លាំង ជី អ៊ិនដាសស្ទ្រី (ខេមបូឌា) បង្កើតរោងចក្រ ផលិតកបន្ទះបំណែកធុងទឹក ៩៥៣៦

៨-៦-២០២១ -ប្រកាសលេខ ១៨៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៩៥៣៩

៨-៦-២០២១ -ប្រកាសលេខ ១៨៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បាវ មេន អ៊ិនដាសស្ទ្រី ឯ.ក បង្កើតរោងចក្រ កែច្នៃជ័រកៅស៊ូ ៩៥៤២

១០-៦-២០២១ -ប្រកាសលេខ ១៨៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន បាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត បង្កើតរោងចក្រ ផលិតស៊ីម៉ងត៍ ៩៥៤៥

១០-៦-២០២១ -ប្រកាសលេខ ១៨៨ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សេង ហ្សុងស៊ីន (ខេមបូឌា) ស្រ្ដីន ព្រីនធីង ឯ.ក បង្កើតរោងចក្រ បោះពុម្ពលើសម្លៀកបំពាក់ ៩៥៤៨

១១-៦-២០២១ -ប្រកាសលេខ ១៩២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យានកាង បាយអូឡូជីខល ថេកណូឡជី ឯ.ក បង្កើតរោងចក្រ កែច្នៃម្ហូបអាហារ ៩៥៥១

១១-៦-២០២១ -ប្រកាសលេខ ១៩៣ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាង ហ៉រ ផលីយូរីសេន មេធៀរៀល (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតអេប៉ុងហ្វ៊ូ ខ្នើយ ស្រោមខ្នើយ កម្រាលពូក គ្រលាត់ពូក គ្រែសាឡុងពូក និងគ្រឿងសង្ហារឹម ៩៥៥៤

១១-៦-២០២១ -ប្រកាសលេខ ១៩៤ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អង្គរ ខ្មែរ ប្រូដាក់ ខូអិលធីឌី បង្កើតរោងចក្រ ផលិតទឹកដោះគោគ្រប់ប្រភេទ ៩៥៥៧

១៦-៦-២០២១ -ប្រកាសលេខ ១៩៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អូសិន គ្រេស្ស៊ី ដាយអ៊ីង & ព្រីនធីង ឯ.ក បង្កើតរោងចក្រ បោកគក់ ជ្រលក់ពណ៌ និងបោះពុម្ព ៩៥៦០


## ៣~ទីស្ដីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


២៥-១១-២០២០ -ប្រកាសលេខ ០០១៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការមណ្ឌលសន្និធិប្រេងឥន្ធនៈលេខ ០០១៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៦៣

៤-១១-២០២០ -ប្រកាសលេខ ០៥១៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥១៤ រថ.អប្រក.លអ ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៦៧

១០-១១-២០២០ -ប្រកាសលេខ ០៥១៨ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥១៨ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៧១

១៧-១១-២០២០ -ប្រកាសលេខ ០៥២៣ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥២៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៧៥

១៧-១១-២០២០ -ប្រកាសលេខ ០៥២៤ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥២៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៧៩

១៧-១១-២០២០ -ប្រកាសលេខ ០៥២៦ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥២៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៨៣

១៧-១១-២០២០ -ប្រកាសលេខ ០៥២៩ រថ.អប្រក.ប្រក ស្ដីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៥២៩ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៨៧

១៧-១១-២០២០ -ប្រកាសលេខ ០៥៣២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៣២ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៩១
១៧-១១-២០២០ -ប្រកាសលេខ ០៥៣៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៣៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៩៥
២៤-១១-២០២០ -ប្រកាសលេខ ០៥៣៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៥៣៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៥៩៩
២៤-១១-២០២០ -ប្រកាសលេខ ០៥៤៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៤៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៦០៣
២៤-១១-២០២០ -ប្រកាសលេខ ០៥៥៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៥៣ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៦០៧
២៤-១១-២០២០ -ប្រកាសលេខ ០៥៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៥៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ៩៦១១
១០-១២-២០២០ -ប្រកាសលេខ ០៦៤៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ
ប្រេងឥន្ធនៈលេខ ០៦៤៩ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ ៩៦១៥

## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

១៣-១០-២០២១ -ប្រកាសលេខ ១៥២ កយ.ប្រក/២១ ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៦១៩

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/[illegible]

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម
ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- ឯកឧត្តម ស៊ាន សូលីឌុធ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោកស្រី សុខ វណ្ណារ៉ែន
២- លោក គាន់ ម៉ុនណារា
៣- លោក នុត យុត្តនា
៤- លោក ឆុំ រឿ
៥- លោក ស៊ាន សំណាង
៦- លោក សេង សុគុណា
៧- លោក ឡុង សុភ័ក្រ
៨- លោក ចាន់ រតនៈ
៩- លោក ប៉េង សុខុម
១០- លោកស្រី ទឹម ពៅធីតា
១១- លោកស្រី គួ សំឡៀង
១២- លោក ម៉ុន សីហៈ
១៣- លោកស្រី ម៉ុង ម៉ានឌី
១៤- លោក សក់ សុវាចា
១៥- លោក សេង សុធា

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោកស្រី ប៊ិន សោភា
២- លោកស្រី វឿន ស៊ីវ៉ាណេ
៣- លោក ឈុន សុជាតិ
៤- លោក គាន់ ម៉ាឡា
៥- លោក សាន សុផា
៦- លោក ស្រ៊ាង ម៉ានថាក់

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១- លោកស្រី ហែម បុប្ផា
២- លោក សាន សុខា
៣- លោក មាស តិរុន

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោកស្រី លិន លីហ្សា

ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក លឹម សុចិត្រា

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក ឈួន ឆវ័ន្ត

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **យ៉ុង ឈេង** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស. ២១១២.៩៩០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃ ពុធ ១១កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែកមានមុខសញ្ញា)**

ឯកតា៖ លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២២ | ឥណទានមុននិយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | 5.300.446,5 | |
| | ៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | | | | 5.300.446,5 | |
| 66 | បន្ទុកហិរញ្ញវត្ថុ | 645.975 | 645.975 | - | 645.975 | 0 |
| 65 | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 1.263.050 | 1.263.050 | - | 1.263.050 | 0 |
| 65 | ការប្រគល់មុខងារអប់រំ និងសុខាភិបាល | 880.248 | 880.248 | - | 880.248 | 0 |
| 69 | ចំណាយមិនបានគ្រោងទុក | 1.618.264 | 1.618.264 | - | 911,5 | 1.617.352,5 |
| 50 | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 1.477.657 | 1.477.657 | - | 1.477.657 | 0 |
| 26 | ការវិនិយោគ | 1.032.605 | 1.032.605 | - | 1.032.605 | 0 |
| | **និយ័តកម្មចូល** | | | 5.300.446,5 | | |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 5.299.535 | | |
| 66 | បន្ទុកហិរញ្ញវត្ថុ | - | - | 645.975 | - | 645.975 |
| 65 | ឧបត្ថម្ភរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ | 31.431 | 31.431 | 2.143.298 | - | 2.174.729 |
| 50 | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | - | - | 1.477.657 | - | 1.477.657 |
| 26 | ការវិនិយោគ | - | - | 1.032.605 | - | 1.032.605 |
| | ៣០- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | | | 911,5 | | |
| 61 | សេវាកម្ម | 175.145,6 | 175.145,6 | 911,5 | - | 176.057,1 |

**មាត្រា២ .–**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ២៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃ សុក្រ ១១កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃ អង្គារ ១៥កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្ដីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១ ០០០ ០០០ ០០០ រៀល (មួយប៊ីលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ជូនអង្គភាពប្រឆាំងអំពើពុករលួយ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទិញគ្រឿងសង្ហារិម សម្ភារ និងបរិក្ខារបច្ចេកទេសបំពាក់ក្នុងអគារការិយាល័យថ្មីរបស់អង្គភាព។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៦៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការសម្រួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៨៨ អនក្រ.តត ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

**មាត្រា១ .-**

ត្រូវបានសម្រួលភារកិច្ចលោក **សោម ផៃ** ពីអគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា មកជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានឋានៈស្មើអគ្គនាយករង។

**មាត្រា២ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៩៤៤.....សហវ.ប្រក

# ប្រកាស
# ស្តីពី
# សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុលទៅជាអគ្គនាយកដ្ឋានសប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ មិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដាឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ

- បានឃើញប្រកាសលេខ ២៧៤ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមផ្ទាល់តាមក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាលក្នុងការពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់
- បានឃើញប្រកាសលេខ ៨៥៦ សហវ.ប្រក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា
- បានឃើញប្រកាសលេខ ១៨៩១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជូនប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងប្រធានរតនាគាររាជធានី ខេត្ត
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.**_

ប្រកាសនេះកំណត់អំពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិការបស់អង្គភាពថវិកានៃក្រសួង ស្ថាប័ន ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និង គណនេយ្យភាព ក្នុងការអនុវត្តថវិកា តាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់លាស់ ដើម្បីសម្រេចបានសមិទ្ធកម្មការងារ ។

**ប្រការ២.**_

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអង្គភាពថវិកាស្ថិតក្រោមឱវាទក្រសួង ស្ថាប័ន ។

## ជំពូកទី២

## សិទ្ធិអំណាច និងការទទួលខុសត្រូវ ក្នុងការអនុវត្តថវិកា

**ប្រការ៣._**

អាណាប័ក ជាអភិបាលកំពូលនៃក្រសួង ស្ថាប័ន ដែលមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ក្រសួង ស្ថាប័ន ក្នុងវង្វង់ឥណទានថវិការបស់ខ្លួន ។

អាណាប័កដើមខ្សែ គឺជារដ្ឋមន្ត្រី ឬប្រធានស្ថាប័នដែលមានសិទ្ធិអំណាចពេញលេញក្នុងការបញ្ជាប្រតិបត្តិការចំណូល និងចំណាយថវិកាដោយផ្ទាល់ និងត្រូវគោរពទៅតាមព្រំដែននៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន ។

អាណាប័កផ្ទេរសិទ្ធិ សំដៅដល់ប្រធានអង្គភាពថវិកានៃក្រសួង ស្ថាប័ន ដែលទទួលបានការប្រគល់សិទ្ធិពីអាណាប័កដើមខ្សែសម្រាប់កិច្ចប្រតិបត្តិការថវិកា ។

អាណាប័កជំនួស គឺជាមន្ត្រីរាជការ ដែលអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិបានជ្រើសតាំង ដើម្បីផ្ទេរសិទ្ធិ ឬជំនួសខ្លួន ដោយផ្អែកលើបទបញ្ញាគណនេយ្យសាធារណៈ ក្នុងករណីដែលអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ អវត្តមាន ឬមានធុរៈ ។

**ប្រការ៤._**

អង្គភាពថវិកា ជាអង្គភាពដែលបានទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ អាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង ស្ថាប័ន ។

អង្គភាពថវិកាមានសិទ្ធិអំណាច និងការទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពការងារ ការរៀបចំ និងការអនុវត្តថវិកាស្របតាមគោលការណ៍កំណត់ដោយក្រសួង ស្ថាប័ន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងាររបស់ខ្លួន ។

អង្គភាពថវិកាមានពីរប្រភេទ គឺអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ។

**ប្រការ៥._**

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ជាអង្គភាពតែមួយគត់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាប័កដើមខ្សែរបស់ក្រសួង ស្ថាប័ន ដែលមានតួនាទី និងភារកិច្ចដឹកនាំ ណែនាំ គាំទ្រ និងសម្របសម្រួលជាមួយគ្រប់អង្គភាពថវិកា ទាំងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញ ទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធមិនពេញលេញ ក្នុងការរៀបចំថវិកា ការអនុវត្តថវិកា ការពិនិត្យ និងការតាមដានការអនុវត្តថវិកា និងបូកសរុបរបាយការណ៍ ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុអាចជាអគ្គលេខាធិការដ្ឋាន ជាអគ្គនាយកដ្ឋាន ឬ ជានាយកដ្ឋាន ដែលទទួលបន្ទុកការងារថវិកានិងហិរញ្ញវត្ថុ របស់ក្រសួង ស្ថាប័ន ។

មន្ទីរជំនាញរាជធានី ខេត្ត ត្រូវសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទរបស់ខ្លួន និងបូកសរុបរបាយការណ៍ រួចផ្ញើមកអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវធានាការរៀបចំថវិកា និងត្រួតពិនិត្យសុពលភាពនៃសំណើសុំចំណាយឱ្យបានត្រឹមត្រូវតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងតាមចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា ជាអាទិ៍មាន ភាពទំនេរនៃឥណទានថវិកា ការរៀបចំសលាកបត្រកត់ត្រាចំណូល ចំណាយថវិកា ការត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចបញ្ជិកាឱ្យបានច្បាស់លាស់ ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវគាំទ្រ និងសម្របសម្រួលជាមួយអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ នូវរាល់ការស្នើសុំចំណាយថវិកា និងការស្នើសុំទូទាត់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវគាំទ្រ និងសម្របសម្រួលបច្ចេកទេសជាមួយអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញដើម្បីឱ្យការអនុវត្តចំណាយប្រព្រឹត្តទៅដោយរលូន និងអនុលោមទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុត្រូវរៀបចំ និងស្នើសុំតែងតាំងរដ្ឋទេយ្យករចំណូល រដ្ឋទេយ្យករចំណូលរង រដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករបុរេប្រទានរង ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួសរបស់ក្រសួង ស្ថាប័ន ដោយអនុលោមទៅតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដែលជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ អាចប្រើរដ្ឋទេយ្យករចំណូល រដ្ឋទេយ្យករបុរេប្រទាន និងភ្នាក់ងារបើកផ្តល់តែមួយរបស់ក្រសួង ស្ថាប័ន ដោយមិនចាំបាច់បង្កើតថ្មី ។

**ប្រការ៦._**

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពថវិកា ជាមន្ត្រីដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សីលធម៌វិជ្ជាជីវៈខ្ពស់ និងជំនាញហិរញ្ញវត្ថុច្បាស់លាស់ ដែលត្រូវបានជ្រើសរើសជាសេនាធិការឱ្យប្រធានអង្គភាពថវិកា ក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដោយត្រូវគោរពតាមវិធាន និងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន ។ ការតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុនៃអង្គភាពថវិកា ត្រូវធ្វើឡើងតាមរយៈប្រកាសប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន តាមសំណើរបស់ប្រធានអង្គភាពថវិកា ។

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពថវិកាមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់អង្គភាពថវិកា ស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន

- ធ្វើទំនាក់ទំនងជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ លើការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិការបស់អង្គភាពថវិកា
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់អង្គភាពថវិកា
- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកាស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- រៀបចំរបាយការណ៍ និងតាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមលេខាធិការរបស់អង្គភាពថវិកា សម្រាប់ការតាមដាន ត្រួតពិនិត្យ និងរៀបចំរបាយការណ៍សមិទ្ធកម្ម
- អនុវត្តការងារផ្សេងទៀតដែលប្រធានអង្គភាពថវិកាប្រគល់ជូន ។

**ប្រការ៧._**

រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ សីលធម៌វិជ្ជាជីវៈខ្ពស់ និងចំណេះដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ។

ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវអនុលោមតាមប្រការ ១០ និង ១១ នៃប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។ ប្រកាសអន្តរក្រសួង ឬ សេចក្តីសម្រេចស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទានត្រូវផ្ញើជូនគណនេយ្យករសាធារណៈ និងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។

កិច្ចដំណើរការអនុវត្ត និងគ្រប់គ្រងចំណាយតាមរជ្ជទេយ្យបុរេប្រទានរបស់រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

រជ្ជទេយ្យករបុរេប្រទាននិងរជ្ជទេយ្យករបុរេប្រទានរងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការទុកដាក់ថែរក្សានូវថវិកាដែលខ្លួនបានទទួល ឬ បានចំណាយ ការទុកដាក់ថែរក្សាលិខិតយុត្តិការ និងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ ។ រជ្ជទេយ្យបុរេប្រទានទាំងអស់ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យនៃអាណាប័ករបស់ខ្លួន ឬប្រធានអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ។ ទន្ទឹមនេះ រជ្ជទេយ្យករបុរេប្រទានត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ពីអគ្គាធិការដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យនៅនឹងកន្លែង ។

**ប្រការ៨._**

រជ្ជទេយ្យករចំណូល ជាអ្នកប្រមូលចំណូលរជ្ជទេយ្យជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ឬតាមរយៈគណនីរបស់រជ្ជទេយ្យករចំណូលនៅតាមធនាគារពាណិជ្ជដៃគូ ដោយបង្វែរចូលគណនីទោលរតនាគារ ។

រដ្ឋទេយ្យករចំណូលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើរដ្ឋទេយ្យចំណូលបានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាស ចំពោះការទុកដាក់ថែរក្សានូវថវិកាដែលខ្លួនបានទទួល ការទុកដាក់ថែរក្សាលិខិតយុត្តិការ និងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ ។

ការស្នើសុំបង្កើតរដ្ឋទេយ្យចំណូល និងការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវអនុលោមតាមប្រការ៤ ប្រការ៥ និងប្រការ៦ នៃប្រកាសលេខ ១៨៩០សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរដ្ឋទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការអនុវត្ត និងការគ្រប់គ្រងរដ្ឋទេយ្យចំណូលរបស់រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

**ប្រការ៩._**

ក្រុមលទ្ធកម្ម គឺជាក្រុមមន្ត្រីរបស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ដែលត្រូវបានចាត់តាំងសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់អង្គភាពថវិកា ក្នុងកម្រិតឥណទានថវិកា និងសិទ្ធិអំណាចប្រគល់ជូនដោយអាណាប័កដើមខ្សែ ។

ក្រុមលទ្ធកម្មដឹកនាំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការផ្តល់សេវាកម្ម និងការផ្តល់សេវាទីប្រឹក្សាឱ្យប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា ។ នីតិវិធីលម្អិតសម្រាប់បង្កើតក្រុមលទ្ធកម្មត្រូវអនុវត្តតាមប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា ។

**ប្រការ១០._**

ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស គឺជាអ្នកទទួលបន្ទុកជំនួសគណនេយ្យករសាធារណៈក្នុងកិច្ចប្រតិបត្តិការទទួលថវិកាសម្រាប់ការចំណាយតាមរយៈគណនីប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្តល់ ដែលបានបើកនៅរតនាគារថ្នាក់កណ្តាលសម្រាប់រដ្ឋបាលកណ្តាល ឬនៅរតនាគាររាជធានី ខេត្តសម្រាប់មន្ទីជំនាញរាជធានី ខេត្ត ។

ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានលក្ខណសម្បត្តិល្អ ដែលអាចគ្រប់គ្រងលើការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ ។

## ជំពូកទី៣
## សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកា
## របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ

### ផ្នែកទី១
### សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ១១.-**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ គឺជាអង្គភាពថវិកាដែលការអនុវត្តចំណាយត្រូវឆ្លងការត្រួតពិនិត្យនិងសម្រេចដោយអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ លើកលែងតែមុខចំណាយជាក់លាក់មួយចំនួន ដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ ។

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ មានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម ÷

១. ការរៀបចំថវិកា

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នសាមី ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័នសាមី ។
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាពស្ថិតក្រោមឱវាទ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗទៀតនៃមាតិកាថវិកា ។
- រៀបចំផែនការលទ្ធកម្ម និងផែនការរដ្ឋទេយ្យបុរេប្រទានប្រចាំឆ្នាំ ផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុដើម្បីបូកសរុប សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ ។
- ចូលរួមពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំកម្រិតជំនាញ និងកម្រិតថ្នាក់ដឹកនាំតាមការអញ្ជើញរបស់អាណាប័កដើមខ្សែ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីចាំបាច់ ។

២. ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងាររបស់ខ្លួន ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានវិភាជជូនដោយអាណាប័កដើមខ្សែ ។
- រៀបចំគម្រោងកម្មវិធីចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសរួចបញ្ជូនមកអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ឱ្យបានទាន់ពេលវេលាកំណត់ ។
- អនុវត្តតាមកម្មវិធីចំណូល ចំណាយ ដែលក្រសួង ស្ថាប័ន កំណត់ឱ្យអនុវត្ត តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ។

- មានសិទ្ធិពេញលេញក្នុងការរៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន និងអនុវត្តកញ្ចប់រដ្ឋទេយ្យបុរេប្រទាន ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានជាធរមាន ។
- មានសិទ្ធិពេញលេញក្នុងការរៀបចំផែនការ និងអនុវត្តចំណាយបេសកកម្មនៅក្នុងប្រទេស រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗ ដែលអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ដោយត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។
- មានសិទ្ធិក្នុងការបញ្ជាចំណាយ ចំពោះមុខសញ្ញាចំណាយដែលបានទទួលការប្រគល់សិទ្ធិ ។
- មានសិទ្ធិស្នើសុំគោលការណ៍ធានាចំណាយ និងការទូទាត់ទៅអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ នូវមុខចំណាយដែលមិនទទួលបានការប្រគល់សិទ្ធិ ។
- អាចស្នើសុំធ្វើចលនាឥណទានថវិកា ឬនិយតកម្មឥណទានថវិកាទៅអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ។
- មិនត្រូវបានប្រគល់សិទ្ធិក្នុងការអនុវត្តការប្រមូលចំណូលទេ ពោលគឺត្រូវរក្សាទុកការអនុវត្តប្រមូលចំណូលនេះនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដោយត្រូវអនុវត្តតាមនិតិវិធីហិរញ្ញវត្ថុជាធរមាន ។

៣. ការពិនិត្យ និងតាមដានការអនុវត្តថវិកា

- ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្ម) ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទដែលបានកំណត់ ។
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

**ប្រការ១២._**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ត្រូវស្នើសុំតែងតាំងដូចខាងក្រោម÷

១. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

២. រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង

៣. ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ១៣._**

អាណាប័ក ត្រូវពិនិត្យ និងវាយតម្លៃអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ជារៀងរាល់ឆ្នាំ ដើម្បីប្រគល់សិទ្ធិឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ស្របតាមលក្ខខណ្ឌវិនិច្ឆ័យជាធរមាន ។

## ផ្នែកទី២

## នីតិវិធីអនុវត្តថវិកា

**ប្រការ១៤._**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ត្រូវគោរពតាមឥណទានថវិកា ដែលបានវិភាជជូនតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនិងចំណាត់ថ្នាក់កម្មវិធីនៃមាតិកាថវិកា និងត្រូវអនុវត្តចំណាយស្របតាមកម្មវិធីចំណូលចំណាយប្រចាំត្រីមាស ដែលបានបែងចែកឥណទានថវិកាទៅតាមខែនីមួយៗនៃឆ្នាំសារពើពន្ធ ។

**ប្រការ១៥.-**

សំណើសុំគោលការណ៍ធានាចំណាយថវិកា និងការទូទាត់ ត្រូវដាក់ជូនអាណាប័កដើមខ្សែ ដើម្បីពិនិត្យនិងចុះហត្ថលេខា តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច តាមរយៈអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួង ស្ថាប័នសាមី ។

សម្រាប់មុខចំណាយដែលត្រូវបានផ្ទេរសិទ្ធិដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ អង្គភាពថវិកាត្រូវស្នើសុំទូទាត់ត្រង់ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច តាមរយៈអ្នកត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័នសាមី ដោយត្រូវគោរពទៅតាមក្របខ័ណ្ឌនៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន និងស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ។ ចំពោះឯកសារពាក់ព័ន្ធ រួមមាន លិខិតស្នើសុំចំណាយ អាណត្តិបើកប្រាក់ សលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ដីកាអមបញ្ចេញអាណត្តិបើកប្រាក់ និងដីកាអមលិខិតយុត្តិការ ត្រូវថតចម្លងជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់កត់ត្រា និងបូកសរុប ដើម្បីជាកម្មវត្ថុនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ។ ទន្ទឹមនឹងនេះ អាណត្តិបើកប្រាក់ ត្រូវចុះលេខនិងកាលបរិច្ឆេទ នៅក្រសួង ស្ថាប័ន សាមី ។ អង្គភាពថវិកាអាចស្នើសុំការគាំទ្រ និងការសម្របសម្រួលពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្នុងករណីចាំបាច់ ។ បរិបថចំណាយ មានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ។

**ប្រការ១៦._**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ទទួលបានសិទ្ធិបញ្ជាចំណាយកញ្ចប់ថវិកា លើមុខសញ្ញាចំណាយមួយចំនួន ដូចខាងក្រោម ÷

១) ប្រាក់បៀវត្ស និងប្រាក់បំណាច់មន្ត្រីរាជការដែលមានទិដ្ឋាការយល់ព្រមពីក្រសួងមុខងារសាធារណៈ និងការបង់សំណែសចំណាយ

២) ប្រាក់បៀវត្សមូលដ្ឋានរបស់មន្ត្រីជាប់កិច្ចសន្យា ដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ និងការបង់សំណែសចំណាយ

៣) ប្រាក់ឧបត្ថម្ភមន្ត្រីរាជការសម្រាលកូន ដែលមានគោលការណ៍ និងរបបកំណត់

៤) ប្រាក់មរណភាព ដែលមានគោលការណ៍ និងរបបកំណត់

៥) ប្រាក់ឧបត្ថម្ភម្ដងគត់ជូននិវត្តជន និងអ្នកសុំឈប់ពីការងារ ដែលមានគោលការណ៍ និងរបបកំណត់

៦) ប្រាក់ឧបត្ថម្ភកូនកំព្រារបស់មន្ត្រីរាជការ

៧) ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យាដែលមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល និងមានកិច្ចសន្យាការងារត្រឹមត្រូវ

៨) ថ្លៃប្រើប្រាស់អគ្គិសនីសម្រាប់ដំណើរការរដ្ឋបាល ដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា និងសាខាសម្រាប់អង្គភាពថវិកាដែលបានគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំ

៩) ថ្លៃប្រើប្រាស់ទឹកស្អាត ដែលផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ និងសាខា សម្រាប់អង្គភាពថវិកាដែលបានគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំ

១០) ថ្លៃសេវាប្រមូលសំរាម និងកាកសំណល់ដែលផ្គត់ផ្គង់ដោយរដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ សម្រាប់អង្គភាពថវិកាដែលបានគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំ

១១) សោហ៊ុយទូរគមនាគមន៍ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា

១២) សោហ៊ុយប្រៃសណីយ៍ដែលផ្ដល់សេវាដោយប្រៃសណីយ៍កម្ពុជា

១៣) ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេសដែលមានគោលរបបកំណត់

១៤) លតាបត្រលើចំណាយបង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន) ដែលជាកម្មសិទ្ធិរបស់ក្រសួង ស្ថាប័ន

១៥) ចំណាយតាមរដ្ឋទេយ្យបុរេប្រទាន

១៦) ចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស

១៧) ចំណាយរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា

១៨) ចំណាយរៀបចំកិច្ចប្រជុំផ្សេងៗ ដែលមានកម្រិតទឹកប្រាក់អតិបរមា ៣ លានរៀល

១៩) ចំណាយបង់ថ្លៃសមាជិកភាពអង្គការអន្តរជាតិ ឬសហព័ន្ធកីឡាអន្តរជាតិ ដែលកម្ពុជាមានកាតព្វកិច្ចត្រូវចូលរួម តាមរយៈកិច្ចព្រមព្រៀង ឬសន្ធិសញ្ញា និងមានវិក្កយបត្រច្បាស់លាស់ ។

អាណាប័កដើមខ្សែ អាចពិនិត្យផ្តល់សិទ្ធិបន្ថែមជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ក្នុងការបញ្ចាចំណាយលើមុខចំណាយមួយចំនួនផ្សេងទៀតតាមការចាំបាច់ ។

**ប្រការ១៧._**

រាល់កិច្ចប្រតិបត្តិការចំណាយ និងការគ្រប់គ្រងថវិកា ត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍ជាអាទិ៍ ដូចខាងក្រោម ÷

- ត្រូវគោរពតាមឥណទានថវិកា ដែលបានវិភាជជូនតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី ។
- កិច្ចប្រតិបត្តិការចំណាយថវិកាត្រូវអនុវត្តតាមប្រភេទចំណាយ និងនីតិវិធីចំណាយ ដូចខាងក្រោម ÷
  - ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ÷ ជាប្រភេទចំណាយតម្រូវឱ្យអនុវត្ត (១) នីតិវិធីចំណាយព្រម និង (២) នីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយមុនបោះផ្សាយអាណត្តិទូទាត់
  - ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ÷ ជាប្រភេទចំណាយតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ មុនបោះផ្សាយអាណត្តិទូទាត់។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់ក្រសួង ស្ថាប័ន ដោយត្រូវអនុលោមតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន ។

- ការទូទាត់ត្រូវបានអនុញ្ញាតក្រោយពេលទំនិញ សំណង់ និងសេវាត្រូវបានត្រួតពិនិត្យ វាយតម្លៃ ឬប្រគល់ ទទួលជាស្ថាពរ ។ អង្គភាពថវិកាត្រូវទទួលបានទំនិញ សំណង់ និងសេវា ពីការបែងចែកដោយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុតាមលទ្ធផលនៃការប្រគល់ ទទួល ដោយកត់ត្រាបរិមាណ និងចំនួនទឹកប្រាក់ចំណាយឱ្យបានច្បាស់លាស់ ។

- ការផ្ទេរចលនាឥណទានថវិកា ឬនិយតកម្មឥណទានថវិកា អាចអនុវត្តបានចាប់ពីត្រីមាសទី២ នៃឆ្នាំថវិកា ដោយត្រូវអនុលោមតាមនីតិវិធីដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ។ អង្គភាពថវិកាត្រូវស្នើសុំទៅអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដោយពន្យល់អំពីមូលហេតុឱ្យបានត្រឹមត្រូវច្បាស់លាស់ អំពីភាពចាំបាច់នៃការផ្ទេរចលនាឥណទានថវិកា ឬនិយតភាពឥណទានថវិកា និងត្រូវធានាថា មិនប៉ះពាល់ដល់លទ្ធផលដែលនឹងរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ។

**ប្រការ១៨._**

ចំពោះការចុះប្រតិបត្តិការចំណាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ត្រូវបញ្ជូនសំណើសុំចំណាយរបស់ខ្លួន ទាំងចំណាយដែលទទួលបានការផ្ទេរសិទ្ធិ ទាំងចំណាយដែលមិនទទួលបានការផ្ទេរសិទ្ធិពីអាណាប័កដើមខ្សែ ទៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ដើម្បីចុះនូវប្រតិបត្តិការចំណាយទៅក្នុងប្រព័ន្ធ FMIS ជំនួស ដោយត្រូវមានកម្មវត្ថុចំណាយតាមចំណាត់ថ្នាក់នៃមាតិកាថវិកាច្បាស់លាស់ និងឥណទានថវិកាទំនេរគ្រប់គ្រាន់ ។ បន្ទាប់ពីទទួលបានការអនុម័តពីអាណាប័កដើមខ្សែលើសំណើសុំចំណាយ ប្រធានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ត្រូវអនុម័តលើប្រតិបត្តិការក្នុងប្រព័ន្ធ FMIS ដែលបានចុះរួច ដើម្បីបញ្ជូនប្រតិបត្តិការបន្តទៅអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ។ បរិបថលម្អិតមានកំណត់ក្នុងឧបសម្ពន្ធទី៣ នៃប្រកាសនេះ ។

## ជំពូកទី ៤

## សិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកា របស់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ

### ផ្នែកទី១

### សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ១៩._**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ គឺជាអង្គភាពថវិកាដែលអាណាប័កដើមខ្សែ បានប្រគល់សិទ្ធិអំណាចពេញលេញ ក្នុងការបញ្ជាចំណូល ចំណាយថវិការបស់អង្គភាពខ្លួន ដោយមិនតម្រូវឱ្យឆ្លងអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងការត្រួតពិនិត្យនិងសម្រេច ពីអាណាប័កដើមខ្សែ ។

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ មានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោម÷

១. ការរៀបចំថវិកា

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន សាមី ជាមួយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងក្រុមការងារថវិកានៃក្រសួង ស្ថាប័ន សាមី ។
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដោយបែងចែកលម្អិតតាមអង្គភាពស្ថិតក្រោមឱវាទ ទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់ផ្សេងៗទៀតនៃមាតិកាថវិកា ។
- រៀបចំផែនការលទ្ធកម្ម និងផែនការរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ សម្រាប់ពិនិត្យនិងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ ។

- ចូលរួមពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំកម្រិតជំនាញ និងកម្រិតថ្នាក់ដឹកនាំ ។

២. ការអនុវត្តថវិកា

- ចាត់ចែងអនុវត្តសកម្មភាពការងារ ក្នុងកម្រិតឥណទានថវិកាប្រចាំឆ្នាំដែលបានវិភាជជូនដោយអាណាប័កដើមខ្សែ ។
- រៀបចំគម្រោងកម្មវិធីចំណូល ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសរួចបញ្ជូនមកអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន ឱ្យបានទាន់ពេលវេលាកំណត់ ។
- អនុវត្តតាមកម្មវិធីចំណូល ចំណាយដែលក្រសួង ស្ថាប័ន កំណត់ឱ្យអនុវត្ត តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ។
- មានសិទ្ធិពេញលេញក្នុងកិច្ចប្រតិបត្តិការចំណូល ។
- មានសិទ្ធិពេញលេញក្នុងការរៀបចំតារាងឧបសម្ពន្ធរង្វាន់ទេយ្យបុរេប្រទាន និងអនុវត្តកញ្ចប់រង្វាន់ទេយ្យបុរេប្រទាន ដោយត្រូវអនុវត្តនីតិវិធីចំណាយតាមរង្វាន់ទេយ្យបុរេប្រទានជាធរមាន ។
- មានសិទ្ធិពេញលេញក្នុងការរៀបចំផែនការ និងអនុវត្តគម្រោងចំណាយបេសកកម្មនៅក្នុងប្រទេស រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗ ដែលអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន ដោយត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន។
- មានសិទ្ធិពេញលេញក្នុងការអនុវត្តចំណាយ ដោយស្នើសុំគោលការណ៍ធានាចំណាយ អនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយក្រុមលទ្ធកម្ម និងស្នើសុំការទូទាត់ ដោយផ្ទាល់ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថ្នាក់កណ្តាល និងទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ថ្នាក់រាជធានី ខេត្ត ដើម្បីទទួលការទូទាត់ដោយផ្ទាល់ពីរតនាគារថ្នាក់កណ្តាល ឬពីរតនាគាររាជធានី ខេត្ត ដោយត្រូវគោរពទៅតាមក្របខ័ណ្ឌនៃសិទ្ធិអំណាច និងមុខងាររបស់ខ្លួន និងស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ ដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ។ អង្គភាពថវិកាអាចស្នើសុំការគាំទ្រ និងការសម្របសម្រួលពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុក្នុងករណីចាំបាច់ ។ ទន្ទឹមនឹងនេះ អាណត្តិបើកប្រាក់ ត្រូវចុះលេខនិងកាលបរិច្ឆេទ នៅអង្គភាពថវិកាផ្ទាល់ ។
- អាចស្នើសុំផ្ទេរចលនាឥណទានថវិកា ឬនិយតកម្មឥណទានថវិកា ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដែលមានចែងក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ។

៣. ការពិនិត្យ និងតាមដានការអនុវត្តថវិកា

- ពិនិត្យតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តថវិកា និងការអនុវត្តសកម្មភាពការងាររបស់ខ្លួន ។

- រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍សមិទ្ធកម្ម) ស្របតាមការណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ/ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន និងផ្ញើជូនអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័ន តាមកាលបរិច្ឆេទដែលបានកំណត់ ។
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តចំណូល ។
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ។

**ប្រការ២០._**

អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ត្រូវបង្កើត និងស្នើសុំតែងតាំងដូចខាងក្រោម÷

១. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

២. រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង

៣.រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ក្នុងករណីមានរដ្ឋទេយ្យចំណូល

៤. ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស

៥. ក្រុមលទ្ធកម្ម ។

**ប្រការ២១._**

អាណាប័កដើមខ្សែ មានសិទ្ធិរក្សាទុកមុខចំណាយមួយចំនួនមិនប្រគល់សិទ្ធិជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងករណីពិនិត្យឃើញថា មុខចំណាយទាំងនោះ មានលក្ខណៈយុទ្ធសាស្ត្រ វេទយិតភាព និងចាំបាច់ក្នុងការអនុវត្តកិច្ចលទ្ធកម្មប្រមូលផ្តុំ ដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង និងចំណេញពេលវេលា ព្រមទាំងអាចកាត់បន្ថយសោហ៊ុយចំណាយ ។

អាណាប័កដើមខ្សែ មានសិទ្ធិរក្សាទុកមុខសញ្ញាចំណូលមួយចំនួន ឬទាំងអស់ មិនប្រគល់សិទ្ធិជូនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ក្នុងករណីពិនិត្យឃើញថា មុខសញ្ញាចំណូលទាំងនោះ មានលក្ខណៈយុទ្ធសាស្ត្រ និងវេទយិតភាព ។

## ផ្នែកទី២
## នីតិវិធីអនុវត្តថវិកា

**ប្រការ២២._**

ការស្នើសុំគោលការណ៍ធានាចំណាយថវិកា និងការទូទាត់ ត្រូវដាក់គ្រង់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈអ្នកត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមផ្ទាល់ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល

សម្រាប់ថ្នាក់រដ្ឋបាលកណ្ដាល និងទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្ដល់ទិដ្ឋាការចំណាយតាមបរិបថ ដូចមានក្នុងឧបសម្ពន្ធទី២ នៃប្រកាសនេះ ។

អភិបាលហិរញ្ញវត្ថុពិនិត្យ និងសម្រេច រួចបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ថ្នាក់កណ្ដាល និងសម្រាប់មន្ទីរជំនាញរាជធានី ខេត្ត ត្រូវបញ្ជូនទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យ សម្រេច និងបើកផ្ដល់ក្នុងនាមគណនេយ្យករសាធារណៈ ។

**ប្រការ២៣.**_

រាល់កិច្ចប្រតិបត្តិការចំណាយ និងការគ្រប់គ្រងថវិកា ត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍ ជាអាទិ៍ ដូចខាងក្រោម ÷

- ត្រូវគោរពតាមឥណទានថវិកាដែលបានវិភាជជូន តាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងចំណាត់ថ្នាក់កម្មវិធី ។
- ត្រូវអនុវត្តចំណាយតាមកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ដែលក្នុងនោះបានបែងចែកឥណទានថវិកាទៅតាមខែនីមួយៗនៃឆ្នាំសារពើពន្ធ ។ អង្គភាពថវិកាអាចបោះផ្សាយអាណត្តិបើកប្រាក់ក្នុងវង្វង់នៃកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសរបស់ខ្លួន ។
- កិច្ចប្រតិបត្តិការចំណាយថវិកាចរន្តត្រូវអនុវត្តតាមប្រភេទចំណាយ និងនីតិវិធីចំណាយដែលរួមមាន÷
  - ចំណាយមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ÷ ជាប្រភេទចំណាយតម្រូវឱ្យអនុវត្ត (១)នីតិវិធីចំណាយព្រម និង (២) នីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយមុនបោះអាណត្តិទូទាត់, និង
  - ចំណាយតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ÷ ជាប្រភេទចំណាយ ដែលនីតិវិធីតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ មុនបោះផ្សាយអាណត្តិទូទាត់ ។ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវរៀបចំដោយក្រុមលទ្ធកម្មរបស់អង្គភាពថវិកាផ្ទាល់ ដោយត្រូវអនុលោមតាមប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា និងតាមការកំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មជាធរមាន ។
